# សូមពិនិត្យរូបសញ្ញានៅពេលប្រើប្រាស់សារធាតុគីមី !

| | រូបសញ្ញា | គ្រោះថ្នាក់ទូទៅ ឬគ្រោះថ្នាក់គីមី | ឧទាហរណ៍ទូទៅស្តីពីវិធានបង្ការជាមុន |
|---|---|---|---|
| គ្រោះថ្នាក់ | <br>(សញ្ញាគ្រាប់បែកផ្ទុះ) | លក្ខណៈផ្ទុះ៖ គ្រោះថ្នាក់ផ្ទុះទ្រង់ទ្រាយធំ<br>លក្ខណៈផ្ទុះ៖ គ្រោះថ្នាក់ឆាបឆេះ ផ្ទុះឆេះ ឬផ្ទុះ<br>គ្រោះថ្នាក់ផ្ទុះនៅពេលត្រូវកម្តៅ | ហាមជក់បារី។ រក្សាទុកតែនៅក្នុងកញ្ចប់ដើមប៉ុណ្ណោះ<br>ហាមរក្សាទុកនៅកន្លែងដែលមានសីតុណ្ហភាពខ្ពស់ ផ្កាភ្លើង និងប្រភពភ្លើង។<br>ក្នុងករណីមានការឆាបឆេះ សូមភៀសខ្លួនចេញ។ កុំព្យាយាមពន្លត់ភ្លើង<br>នៅពេលភ្លើងឆេះរាលដាលដល់គ្រឿងផ្ទុះ។<br>ចូរបោះចោលសារធាតុនិងវត្ថុផ្ទុកសារធាតុទាំងនោះឲ្យស្របទៅតាមការកំណត់របស់ច្បាប់។ |
| | <br>(សញ្ញាអណ្តាតភ្លើង) | ឧស្ម័នឬថ្នាំបាញ់ដែលអាចឆេះខ្លាំង<br>វត្ថុរាវឬចំហាយដែលងាយឆេះខ្លាំង<br>វត្ថុរឹងដែលអាចឆេះ<br>គ្រោះថ្នាក់បង្កជាអគ្គិភ័យនៅពេលត្រូវកម្តៅ<br>ហានិភ័យបង្កជាការឆាបឆេះដោយឯកឯងនៅពេលត្រូវខ្យល់<br>បញ្ចេញឧស្ម័នដែលងាយឆាបឆេះនៅពេលត្រូវទឹក | រក្សាទុកឲ្យឆ្ងាយពីកម្តៅ ផ្ទៃក្តៅ ផ្កាភ្លើង អណ្តាតភ្លើង និង ប្រភពចំហេះផ្សេងៗទៀត។ ហាមជក់បារី។<br>រក្សាទុកនៅតំបន់ដែលមានខ្យល់ចេញចូលល្អ។<br>ការណែនាំបន្ថែម៖ ប្រសិនបើប៉ះស្បែក៖ លាងឬជម្រះវាចេញពីស្បែក។ ត្រាំទឹកត្រជាក់។ - វិធីនេះអាចមិនត្រូវគ្រប់ស្ថានភាពនោះទេ ព្រោះពេលខ្លះគួរចៀសវាងការប្រើទឹក។ |
| | <br>(សញ្ញាអណ្តាតភ្លើងនៅលើរង្វង់) | គ្រោះថ្នាក់បង្កជាការឆេះ ឬរឹតតែធ្វើឲ្យឆេះខ្លាំងឡើង<br>គ្រោះថ្នាក់បង្កជាការឆេះ ឬការផ្ទុះ<br>គ្រោះថ្នាក់ដែលរឹតតែធ្វើឲ្យឆេះខ្លាំងឡើង | រក្សាទុកឲ្យឆ្ងាយពីកម្តៅ ផ្ទៃក្តៅ ផ្កាភ្លើង អណ្តាតភ្លើង និង ប្រភពចំហេះផ្សេងៗទៀត។ ហាមជក់បារី។<br>រក្សាទុកឲ្យឆ្ងាយពីវត្ថុធាតុដែលអាចឆេះ។<br>រក្សាទុកនៅដាច់តែឯង។ |
| | <br>(សញ្ញាបំពង់ឧស្ម័ន) | ឧស្ម័នរងសម្ពាធ៖ គ្រោះថ្នាក់ផ្ទុះឡើងនៅពេលត្រូវកម្តៅ<br>ឧស្ម័នពង្រាវដែលគេបង្កក៖ គ្រោះថ្នាក់ដល់ស្បែកឬបង្ករការរលាកស្បែកដោយសារធាតុត្រជាក់ | ការពារកុំឲ្យត្រូវពន្លឺថ្ងៃ។ រក្សាទុកនៅទីកន្លែងដែលមានខ្យល់ចេញចូលល្អ។<br>ពាក់ស្រោមដៃដែលការពារធាតុត្រជាក់ និងពាក់របាំងមុខឬវ៉ែនតាការពារភ្នែក។<br>ប្រើទឹកក្តៅឧណ្ហៗដើម្បីរំលាយផ្នែកដែលកក។ កុំត្រដុសនៅត្រង់កន្លែងដែលរងផលប៉ះពាល់។ ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។ |
| | <br>(សញ្ញាការកាត់ឬស៊ី) | អាចកាត់ឬស៊ីលោហធាតុ | រក្សាទុកតែនៅក្នុងកញ្ចប់ដើមប៉ុណ្ណោះ |
| គ្រោះថ្នាក់ដល់សុខភាព | | ធ្វើឲ្យរលាកស្បែកនិងប៉ះពាល់ភ្នែកធ្ងន់ធ្ងរ | បង្ការកុំឲ្យប៉ះស្បែកនិងភ្នែក។<br>បន្ទាប់ពីប៉ះពាល់ ចូរលាងសម្អាតកន្លែងដែលប៉ះពាល់ជាបន្ទាន់<br>លាងសម្អាតខ្លួនប្រាណនិងសម្លៀកបំពាក់ឲ្យបានស្អាតល្អបន្ទាប់ពីប្រើប្រាស់រួច។<br>ស្លៀកសម្លៀកបំពាក់ ស្រោមដៃ និងវ៉ែនតាការពារសុវត្ថិភាព។ |
| | <br>(សញ្ញាក្បាលខ្មោច) | បង្កជាការពុលធ្ងន់ធ្ងរ (អាចស្លាប់ឬពុល)នៅពេលហឺតចូល លេបចូល ឬប៉ះស្បែក។ | ហាមហឺតចូល ដាក់ចូលក្នុងមាត់ ឬដាក់លើស្បែក។<br>ប្រសិនបើបានប៉ះពាល់ សូមស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។<br>សម្រាប់តែប្រើនៅខាងក្រៅឬនៅទីកន្លែងដែលមានខ្យល់ចេញចូលល្អប៉ុណ្ណោះ។<br>ពាក់ម៉ាស់ សម្លៀកបំពាក់និងស្រោមដៃការពារ។<br>រក្សាទុកដោយចាក់សោឲ្យបានគត់មុត។ |
| | <br>(សញ្ញាគ្រោះថ្នាក់ដល់សុខភាព) | គ្រោះថ្នាក់បង្កជាជំងឺតំណពូជ<br>គ្រោះថ្នាក់បង្កជាជំងឺមហារីក<br>គ្រោះថ្នាក់ពុលចំពោះប្រព័ន្ធបន្តពូជឬផលប៉ះពាល់ដល់ទារកក្នុងផ្ទៃ<br>គ្រោះថ្នាក់បង្កជាអាឡាក់ស៊ី ជំងឺហឺត ឬពិបាកដកដង្ហើមនៅពេលហឺតចូល<br>ការពុលចំពោះសរីរាង្គជាក់លាក់ក្នុងរាងកាយ<br>បង្កជាការពុលធ្ងន់ធ្ងរនៅពេលស្រូបចូលក្នុងផ្លូវដង្ហើម (ដំណកដង្ហើម) | ហាមប៉ះស្បែក។<br>ហាមហឺតចូល។<br>ពាក់ម៉ាស់ ស្រោមដៃនិងសម្លៀកបំពាក់ការពារ។<br>ទីកន្លែងទុកដាក់ត្រូវមានខ្យល់ចេញចូលល្អ។<br>ពិគ្រោះជាមួយវេជ្ជបណ្ឌិតប្រសិនបើសង្កេតឃើញភាពខុសប្រក្រតីឬសង្ស័យថាបានប៉ះពាល់។ |
| | <br>(សញ្ញាឧទាន) | ការពុលធ្ងន់ធ្ងរ។ មានគ្រោះថ្នាក់នៅពេលហឺតចូល ឬលេបចូល ឬប៉ះពាល់ស្បែក<br>ធ្វើឲ្យរលាកភ្នែកនិងស្បែកធ្ងន់ធ្ងរ<br>គ្រោះថ្នាក់បង្កជាអាឡាក់ស៊ីស្បែក<br>គ្រោះថ្នាក់បង្កជាការរលាកដល់សរីរាង្គប្រព័ន្ធដង្ហើម អាការៈងងុយគេង ឬវិលមុខ | ហាមហឺតចូល។<br>ទាក់ទងវេជ្ជបណ្ឌិត ប្រសិនបើអ្នកមានអារម្មណ៍មិនស្រួលខ្លួន។<br>ពាក់ឧបករណ៍ការពារខ្លួន។ |
| គ្រោះថ្នាក់ដល់បរិស្ថាន | | ប៉ះពាល់ដល់សុខភាពសាធារណៈ និងបរិស្ថាន ដោយបំផ្លាញស្រទាប់អូសូននៅក្នុងបរិយាកាសខាងលើ | សម្រាប់ព័ត៌មានស្តីពីការប្រមូលឬកែច្នៃឡើងវិញ ចូរទាក់ទងទៅក្រុមហ៊ុនផលិតឬអ្នកផ្គត់ផ្គង់។ |
| | <br>(សញ្ញាបរិស្ថាន) | ពុលខ្លាំងចំពោះភាវៈរស់ក្នុងទឹក | ហាមបញ្ចេញទៅក្នុងបរិស្ថាន។<br>ចូរបោះចោលសារធាតុនិងវត្ថុផ្ទុកសារធាតុទាំងនោះឲ្យស្របទៅតាមការកំណត់របស់ច្បាប់។ |

សម្គាល់៖ វិធានបង្ការជាមុនដែលបានរៀបរាប់ទាំងនេះគឺជាសេចក្តីដកស្រង់ទូទៅ។